# ការរក្សាគម្លាតសង្គម (~ ថ្ងៃទី១៧ ខែតុលា)

## - ភាពងាយស្រួលសម្រាប់អ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំង និង ការពង្រីកកម្មវិធីព្យាបាលតាមផ្ទះ -

### □ នៅតំបន់ទីក្រុងនិងជុំវិញទីក្រុង កម្រិត៤ · នៅតំបន់មិនមែនទីក្រុង កម្រិត៣ ((ច័ន្ទ)ថ្ងៃទី៤ ខែតុលា ម៉ោង០ ~ (អាទិត្យ) ថ្ងៃទី២៧ ខែតុលា ម៉ោង២៤)

* នៅតំបន់មិនមែនទីក្រុង មានចំនួនប្រជាជនក្រោម ១០ម៉ឺននាក់ តាមខេត្ត/ក្រុង គឺការកែតម្រូវកម្រិតដោយស្វ័យត

◦ សម្រាប់ការពិចារណាសរុប អំពីការគ្រប់គ្រងស្ថានការណ៍វិធានការបង្ការ និងការរំពឹងទុកសម្រាប់ការផ្លាស់ប្តូរមួយជំហានម្តងៗ ដើម្បីត្រលប់មកជីវិតប្រចាំថ្ងៃធម្មតាវិញនោះ ដោយផ្តោតលើអ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំង

| ការបែងចែក | | វិធានការដើម | ការផ្លាស់ប្តូរ |
|---|---|---|---|
| ពិធីរៀបមង្គលការ (កម្រិត ៣,៤ ដូចគ្នា) | | **អនុញ្ញាតរហូតដល់ ៤៩នាក់**<br>*ពិធីមង្គលការដោយគ្មានការផ្តល់អាហារ អនុញ្ញាតអ្នកចូលរួមបានរហូតដល់ ៩៩នាក់ | **ត្រូវបានពង្រីកបន្ថែម សម្រាប់តែអ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំង**<br>▲ពិធីរៀបមង្គលការដែលមានផ្តល់អាហារ៖ សម្រាប់អ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំង អាចបន្ថែមបាន រហូតដល់ ៥០នាក់<br>⇒ ចំនួនមនុស្សដែលអនុញ្ញាតឱ្យចូលរួម **រហូតដល់ ៩៩នាក់**<br>▲ពិធីរៀបមង្គលការ ដោយគ្មានអាហារ៖ សម្រាប់អ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំង អាចបន្ថែមបាន រហូតដល់ ១០០នាក់<br>⇒ ចំនួនមនុស្សដែលអនុញ្ញាតឱ្យចូលរួម **រហូតដល់ ១៩៩នាក់** |
| ពិធីខួបកំណើតលើកដំបូង | កម្រិត៣ | ត្រូវបានអនុញ្ញាត រហូតដល់ ១៦នាក់ | **ចំនួនអ្នកដែលអនុញ្ញាតឱ្យចូលរួម រហូតដល់ ៤៩នាក់ សម្រាប់តែអ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំងប៉ុណ្ណោះ**<br>⇒ពីអតិបរិមាដើម ១៦→អាចបានរហូតដល់ ៤៩នាក់ |
| | កម្រិត៤ | ការជួបជុំឯកជន មានកំណត់ចំនួនអ្នកចូលរួម (មុនម៉ោង១៨ ចំនួន ៤នាក់, ក្រោយម៉ោង១៨ ចំនួន២នាក់) | **ពង្រីកចំនួនអ្នកដែលអនុញ្ញាតឱ្យជួបជុំ រហូតដល់ ៤៩នាក់ សម្រាប់តែអ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំងប៉ុណ្ណោះ**<br>⇒វិធានការដើម មុនម៉ោង១៨ ចំនួន ៤នាក់, ក្រោយម៉ោង១៨ ចំនួន២នាក់ →អាចពង្រីករហូតដល់ ចំនួន៤៩នាក់ ដោយមិនកំណត់ពីពេលវេលា |
| កន្លែងកីឡាខាងក្រៅ (តំបន់ កម្រិត៤) | | ការជួបជុំឯកជន មានកំណត់ចំនួនអ្នកចូលរួម (មុនម៉ោង១៨ ចំនួន ៤នាក់, ក្រោយម៉ោង១៨ ចំនួន២នាក់) | **បន្ថែមសម្រាប់តែអ្នកដែលបានបញ្ចប់ការចាក់វ៉ាក់សាំង និងត្រូវបានអនុញ្ញាតឱ្យមានចំនួនមនុស្សតិចបំផុត ដែលអាចលេងកីឡា(១,៥ដង នៃចំនួនអ្នកចូលរួមព្រឹត្តិការណ៍កីឡានីមួយៗ)**<br>⇒ឧទាហរណ៍) កីឡាវាយកូនបាល់ ដោយត្រូវការចំនួនអ្នកលេងយ៉ាងតិច១៨នាក់, **ត្រូវបានអនុញ្ញាតរហូតដល់ ២៧នាក់(ចំនួនអ្នកលេង ១៨នាក់ + ៩នាក់)។** |

### □ ការពង្រីកការព្យាបាលតាមផ្ទះ

◦ តាមការពិចារណាពីការកាត់បន្ថយអត្រាភាពធ្ងន់ធ្ងរនៃជំងឺនេះ ដោយយោងតាមការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនអ្នកឆ្លងជំងឺកូវីដ និងអត្រានៃការចាក់វ៉ាក់សាំង នឹងមានការពង្រីកពីការអនុវត្តចំពោះអ្នកជំងឺធនស្រាល·គ្មានអាការៈរោគ។

- អ្នកទទួល: អាចអនុវត្តចំពោះអ្នកឆ្លងជំងឺកូវីដធនស្រាល·គ្មានអាការៈរោគ(មិនរាប់បញ្ចូលបរិយាកាសលំនៅដ្ឋានដែលងាយនឹងឆ្លងមេរោគ)
- កាកសំណល់: ការចោលកាកសំណល់ប្រើប្រាស់ប្រចាំថ្ងៃ(ក្រោយ៣ថ្ងៃ បន្ទាប់ពីបញ្ចប់ការព្យាបាលនៅផ្ទះ, ដាក់ក្នុងថង់ពីរជាន់បិទឱ្យជិត និង បាញ់ថ្នាំសម្លាប់មេរោគផ្នែកខាងក្រៅ)

<បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី 1577-1366>